ន.ស/រកម/១២១៤/០២៦

ព្រះរាជក្រម

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានភូមិជាតិសាសនា រក្ខិតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជ្ជបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ លើកម្រង និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ នាសប័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច្បាប់
ស្តីពី
ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង
ឆ្នាំ ២០១៥

ជំពូកទី ៣

បទប្បញ្ញត្តិស្តីពីពន្ធដារ

មាត្រា ១១.-

មាត្រា ៤៧ នៃច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈឆ្នាំ ១៩៩៧ ត្រូវបានកែប្រែដូចខាងក្រោម ៖

មាត្រា៤៧.-ថ្មី

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជកតាមអត្រាកំណើនតាមថ្នាក់ ដូចតទៅ ៖

ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ				អត្រាពន្ធ
ពី	០៛	ដល់	៨០០ ០០០៛	០%
ពី	៨០០ ០០១៛	ដល់	១ ២៥០ ០០០៛	៥%
ពី	១ ២៥០ ០០១៛	ដល់	៨ ៥០០ ០០០៛	១០%
ពី	៨ ៥០០ ០០១៛	ដល់	១២ ៥០០ ០០០៛	១៥%
		លើសពី	១២ ៥០០ ០០០៛	២០%

មាត្រា ១២.-

មាត្រា ២៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ ១១ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានកែប្រែដូចខាងក្រោម ៖

មាត្រា ២៩.-ថ្មី

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវបង់ដោយកម្មសិទ្ធិករ ចំពោះដីដែលពុំមែនជាកម្មវត្ថុនៃពន្ធលើ អចលនទ្រព្យ ។

មាត្រា ១៣.-

មន្ត្រីពន្ធដារទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ឲ្យពិនិត្យ បទល្មើសរលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីពន្ធដារ ត្រូវកំណត់ដោយប្រកាសរួមរបស់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ៦

អវសានប្បញ្ញត្តិ

មាត្រា ១៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៧.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែ ឆ្នូ ឆ្នាំ២០១៤

ខ.ស.ព.ស.២៥៥៨.គ.ស.២០១៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
អូន ព័ន្ធមុនីរ័ត្ន

លេខ:១៤៨៦ **ស.ណ**
សំណៅដែលមានភ្ជាប់ជាការចែកជូនរួយ
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឆ្នូ ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សុខា